ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

# សេចក្ដីប្រកាសព័ត៌មាន
# ប្រកាសស្ដីពី ហានិភ័យឥណទានសម្រាប់អនុបាតភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ របស់ធនាគារជាតិនៃកម្ពុជា

សាជីវកម្មធានាឥណទានកម្ពុជា (CGCC) មានកិត្តិយសសូមជម្រាបជូនគ្រឹះស្ថានហិរញ្ញវត្ថុចូលរួមរបស់ CGCC ឱ្យបានជ្រាបថា នាថ្ងៃទី២៩ មិថុនា ឆ្នាំ២០២៣ ធនាគារជាតិនៃកម្ពុជា បានដាក់ឱ្យអនុវត្ត **“ប្រកាសស្ដីពី ហានិភ័យឥណទានសម្រាប់អនុបាតភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ”**។ តាមរយៈសេចក្ដីប្រកាសព័ត៌មានរបស់ ធនាគារជាតិនៃកម្ពុជា នាថ្ងៃដដែល ប្រកាសស្ដីពី ហានិភ័យឥណទានសម្រាប់អនុបាតភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើនេះ មានគោលបំណងដាក់ចេញនូវវិធានការនៃការថ្លឹងហានិភ័យឥណទានយ៉ាងទូលំទូលាយ ដែលការថ្លឹងនេះ មានកម្រិតខុសៗគ្នាផ្អែកលើ ប្រភេទឥណទាន អ្នកខ្ចី ឬសមភាគី និងឆ្លុះបង្ហាញពីកម្រិតហានិភ័យដែលគ្រឹះស្ថានអាចប្រឈមជាក់ស្ដែង សំដៅពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងហានិភ័យ។

សេចក្ដីប្រកាសព័ត៌មាន របស់ធនាគារជាតិនៃកម្ពុជា ក៏បានលើកឡើងផងដែរ ពីការដាក់វិធានការប្រុងប្រយ័ត្ន និងថ្លឹងថ្លែង និងគិតគូរយ៉ាងម៉ត់ចត់ដល់ការជំរុញការអភិវឌ្ឍវិស័យធនាគារនិងហិរញ្ញវត្ថុ និងកំណើនសេដ្ឋកិច្ចជាតិ ព្រមទាំងចូលរួមជាមួយរាជរដ្ឋាភិបាល ក្នុងការជំរុញការអនុវត្តគោលនយោបាយពាក់ព័ន្ធ ដែលក្នុងនោះក៏មាន ការយកចិត្តទុកដាក់ពិសេសចំពោះ **“ការគាំទ្រដល់យន្តការធានាឥណទានដែលបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជា ដូចជា សាជីវកម្មធានាឥណទានកម្ពុជា (CGCC) ដោយការថ្លឹងហានិភ័យសូន្យភាគរយចំពោះចំណែកឥណទានដែលត្រូវបានធានា ដើម្បីសម្រួលឱ្យសហគ្រាសធុនមីក្រូ តូច និងមធ្យម ទទួលបានប្រភពទុនកាន់តែច្រើនជាងមុន”**។

គួរបញ្ជាក់ផងដែរថា សាជីវកម្មធានាឥណទានកម្ពុជា គឺជាក្រុមហ៊ុនធានាឥណទានមុនដំបូងបង្អស់នៅកម្ពុជា ដែលត្រូវបានសម្រេចបង្កើតឡើងដោយ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** ជាសហគ្រាសសាធារណៈ ក្រោមអាណាព្យាបាលបច្ចេកទេស និងហិរញ្ញវត្ថុ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ បេសកកម្មចម្បងរបស់សាជីវកម្មធានាឥណទានកម្ពុជា គឺផ្ដល់ការធានាឥណទានលើកម្ចី ដែលផ្ដល់ឱ្យអាជីវកម្មដើម្បីចែករំលែកហានិភ័យជាមួយស្ថាប័នផ្ដល់កម្ចី និងបង្កើនបរិយាបន្នហិរញ្ញវត្ថុ៕

*ថ្ងៃចន្ទ ១រោច ខែបឋមសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧*
*រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២៣*

មជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច ជាន់ទី១៩ មហាវិថីអូស៊ីអាយស៊ី (កែងផ្លូវអូរវៀង) ភូមិកៀនឃ្លាំង សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ គេហទំព័រ:www.cgcc.com.kh លេខទូរស័ព្ទ:(+៨៥៥) ២៣ ៧២២ ១២៣ អ៊ីម៉ែល:info@cgcc.com.kh
Business Development Center, 19th Floor, OCIC Blvd.(Corner of Street Oveng), Phum Kean Klaing, Sangkat Chroy Changvar, Khan Chroy Changvar, Phnom Penh. Website: www.cgcc.com.kh, Tel:(+855) 23 722 123, Email:info@cgcc.com.kh